# ការការពារ អភិរក្ស គ្រប់គ្រង និង ការប្រើប្រាស់ធនធានជលផល ប្រកបដោយនិរន្តរភាព

So Nam, Nao Thuok, Leng Sy Vann, Chan Tong Yve
Fisheries Administration, Ministry of Agriculture, Forestry and Fisheries, Phnom Penh, Cambodia

*For disseminations to Commune Council members*
*December 2006*
*Published in Cambodia Fisheries Magazine Vol. 9 (2007)*

## ១, សារៈសំខាន់ធនធានជលផលនៃព្រះរាជាណាចក្រកម្ពុជា

ត្រី និង វិស័យជលផលធ្លាប់មានតួនាទីដ៏សំខាន់ជាយូរយារណាស់មកហើយសំរាប់ប្រជាជនកម្ពុជា ។ វាជាប្រភពចំបងនៃអាហាររូបត្ថម្ភនៅក្នុងរបបអាហារប្រចាំថ្ងៃ និង ជាប្រភពប្រាក់ចំណូលយ៉ាងសំខាន់ ហើយ ក៏មានសារៈសំខាន់ផងដែរ ជាពិសេសខាងវិស័យវប្បធមិ ។ វិស័យជលផលកម្ពុជា បាននឹងកំពុងផ្តល់មុខរបរយ៉ាងសំខាន់បំផុតដល់ប្រជាពលរដ្ឋជាងប្រាំមួយលាននាក់ដែលស្មើនឹង៤៥,៥%នៃប្រជាជនទូទាំងប្រទេស (១០,៥% សំរាប់ការនេសាទជាលក្ខណះអាជីព និង ៣៥% សំរាប់ការនេសាទចិញ្ចឹមជីវិត) ជាពិសេសប្រជាជន ដែលរស់នៅតាមដងទន្លេនានា ជុំវិញបឹងទន្លេសាប និង នៅតាមតំបន់ឆ្នេរ ។

ចាប់តាំងពីឆ្នាំ២០០០ ផលិតផលត្រីទឹកសាបកម្ពុជា ត្រូវជាប់ចំណាត់ថ្នាក់ទី៤លើពិភពលោក បន្ទាប់ពីប្រទេសធំចំនួនបីមាន ចិន ឥណ្ឌា និង បង់ក្លាដេស ប៉ុន្តែ បើគិតពីផលិតផលត្រីទឹកសាបដែលទទួលបានដោយប្រជាជនម្នាក់ៗវិញប្រទេសកម្ពុជាត្រូវជាប់ចំណាត់ថ្នាក់ទី១ លើពិភពលោក ។

ប្រជាជនកម្ពុជាគឺជាជនជាតិមួយក្នុងចំណោមជនជាតិជាច្រើនដែលបានហូបត្រីច្រើនជាងគេលើពិភពលោក ។ ប្រជាជនកម្ពុជាម្នាក់ៗ ហូបត្រីស្រស់ ពី ៣៥ គក្រ ទៅ ៤០ គក្រ/ឆ្នាំ ។ បើសិនជាគិតទាំងត្រីស្រស់ និង ត្រីកែច្នៃ (ប្រហុក ផ្អើរ និង ងៀត) ប្រជាជនកម្ពុជាម្នាក់ៗ ហូបត្រីអស់ ៦៧គក្រ/ឆ្នាំ ។ តួលេខនេះ គឺខ្ពស់ជាងប្រទេសជាច្រើនលើពិភពលោក ដែលប្រជាជនម្នាក់ហូបត្រីពី ១៥ គក្រ ទៅ៩០ គក្រ/ឆ្នាំ ។ លើសពីនេះទៅទៀត ប្រហុក គឺជាប្រភេទម្ហូបអាហារប្រចាំថ្ងៃរបស់ប្រជាជនពលរដ្ឋខ្មែរ ហើយ ក៏អាចនិយាយបានថា ប្រហុក ជានិមិត្តសញ្ញា រឺ អត្តសញ្ញាណខ្មែរ ហើយ ជាម្ហូបអាហារសំខាន់បំផុតសំរាប់ប្រជាជនខ្មែរទូទាំងប្រទេស ជាពិសេសប្រជាជនរស់នៅតាមជនបទឆ្ងាយពីដងទន្លេនានា ដែលយកប្រហុកធ្វើជាម្ហូបជំនួសត្រីស្រស់ សាច់មាន់ ជ្រូក និង សាច់គោ ។ សព្វថ្ងៃនេះ គ្មានប្រភេទត្រីណាក្រៅពីត្រីទឹកសាបទេ ដែលអាចយកមកធ្វើប្រហុកបាន ។

បច្ចុប្បន្ននេះ ប្រទេសកម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេសនានាលើពិភពលោក ដែលសំបូរប្រភេទត្រីទឹកសាប និង ទឹកប្រៃ ដែលមានចំនួនជាង១០០០ប្រភេទ ក្នុងនោះប្រភេទត្រីទឹកសាប មានជាង៥០០ប្រភេទ និង ត្រីទឹកប្រៃមានជាង

៧០០ប្រភេទ ។ នេះជាមោទនភាពរបស់ប្រទេសកម្ពុជា ដែលមានបឹងទន្លេសាបជាបឹងមួយធំជាងគេ និង សំបូរត្រីជាងគេនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ បឹងនេះ មានត្រីជាង២០០ប្រភេទ ដែលបានផ្តល់ផលិតផលត្រីជាង៦០ភាគរយនៃផលិតផលត្រីទឹកសាបសរុបនៃប្រទេសកម្ពុជា ។ ផលិតផលត្រីទឹកសាបសរុបនៃប្រទេសកម្ពុជា មានជាង៤០០,០០០តោន/ឆ្នាំ ដែលមានតម្លៃជាង៣០០លានដុល្លាអាមេរិច ។ ប្រទេសកម្ពុជា មានប្រភេទត្រី ដែលតូចជាងគេមានប្រវែង ២,៥ សម រហូតដល់ប្រភេទត្រីធំបំផុតលើពិភពលោក ដូចជាត្រីរាជមានប្រវែង ៣ម និង មានទំងន់ ជាង៣០០គក្រ ត្រីគល់រាំង មានប្រវែងជាង ២ម និង មានទំងន់ ជាង ២០០គក្រ និង ត្រីបបែល មានប្រវែង ៤ម និង មានទំងន់ជាង១៥០គក្រ ។ សមុទ្រកម្ពុជាក៏សំបូរដោយធនធានជលផលដែរ ផលិតផលត្រីសមុទ្រមានជាង៦០,០០០តោន/ឆ្នាំ

អ្វីដែលហៅថា ការការពារ អភិរក្ស ការគ្រប់គ្រង និង ការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព? ការការពារ អភិរក្ស ការគ្រប់គ្រង និង ការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព គឺជាវិធីសាស្ត្រនៃ ការការពារ អភិរក្ស ការគ្រប់គ្រង និង ការប្រើប្រាស់ ធនធានជលផល ដើម្បីបំពេញតម្រូវការជីវភាពរស់នៅរបស់ប្រជាជនយើងជំនាន់បច្ចុប្បន្ន ព្រមទាំងរបស់កូនចៅយើងជំនាន់ក្រោយនាពេលអនាគត ។

ពាក់ព័ន្ធបញ្ហានេះ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែនជាប្រមុខរាជរដ្ឋាភិបាល បានគ្រើនរំលើក ដល់ គ្រប់ក្រសួងស្ថាប័ននាយកដ្ឋាន និង មន្ទីរជំនាញ ខេត្ត ក្រុងទាំងអស់ ត្រូវតែសហការជាមួយអង្គការអភិវឌ្ឍន៍ជាតិ និង អន្តរជាតិ ដើម្បីបញ្ចូលអាទិភាពផ្សេងៗដែលពាក់ព័ន្ធ នឹង វិស័យជលផលទៅក្នុងផែនការអភិវឌ្ឍន៍របស់ខ្លួនជាដាច់ខាត ហើយ ត្រូវធ្វើយ៉ាងណាស្តារប្រទេសរបស់យើងឡើងវិញឱ្យបានដូចពាក្យស្លោកដែលបានចែងថា " ទីណាមានទឹក ទីនោះមានត្រី " ។

ដើម្បីអនុវត្តន៏នូវអនុសាសន៏របស់រាជរដ្ឋាភិបាល និង ធានា ការការពារ អភិរក្ស ការគ្រប់គ្រង និង ការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាពសំរាប់កូនចៅជំនាន់ក្រោយៗទៀត រាជរដ្ឋាភិបាលតាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានជំរុញពុះពារគ្រប់ឧបសគ្គ និង ប្រើប្រាស់ប្រភពធនធានដែលមាន រហូតដល់បានសំរេចនូវវិធានការទាំងឡាយ ដែលមានចរិក ជាយុទ្ធសាស្ត្រ ខ្លី និង យូរអង្វែង និងអនុវត្តការងារជលផល ជាច្រើនទទួលបានលទ្ធផលជាវិជ្ជមានជាបន្តបន្ទាប់រហូតដល់ បច្ចុប្បន្ន។

## ២, លទ្ធផលទទួលបានពីឆ្នាំ ២០០២ ដល់ បច្ចុប្បន្ន

### ២.១ ការគ្រប់គ្រងការធ្វើនេសាទ

ការគ្រប់គ្រងការធ្វើនេសាទទឹកសាបនៅប្រទេសកម្ពុជាមានចំនួនបីប្រភេទ គឺ ការនេសាទជាលក្ខណៈគ្រួសារ ការនេសាទជាលក្ខណៈសិប្បកម្ម និង ការនេសាទជាលក្ខណៈឧស្សាហកម្ម ។ ដោយធ្វើសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និង សមត្ថកិច្ចជំនាញ ជាពិសេសជាមួយរដ្ឋអំណាចមូលដ្ឋាន ចូលរួមបង្ក្រាបការធ្វើនេសាទខុសច្បាប់ ហើយ ចាប់តាំងពីឆ្នាំ ២០០២ ដល់ បច្ចុប្បន្ន បានរឹបអូស និង បំផ្លាញចោលវត្ថុតាងដូចជា របាំងស្បៃមុងចំនួន ៣.៨១៣.៣៣៩ មាត់ លូស្បៃមុង ចំនួន ៦០.៣១៧ មាត់ អួនស្បៃមុងចំនួន ៥. ២១៨ វង់ អាំងវែទ័រអាគុយចំនួន ២១.៥១៣ គ្រឿង ដាយចាប់កូនត្រីប្រាម្បៀចំនួន

២២៣ មាត់ ដាយត្រីលិញចំនួន ១៣១ មាត់ របាំងព្រួលចំនួន ៤៥៦.៧១៧ ម៉ែត្រ យ៉ាំងការអួនអូសចំនួន ២០វង់ សំរាស់ចំនួន ៣០០.៦៧២ ម៉ែត្រការ៉េ និង ដងឆក់ ៤៥៧ គូរ ។ ចំពោះការគ្រប់គ្រងការធ្វើនេសាទសមុទ្រវិញ បានធ្វើឡើងដោយសហការជាមួយការិយាល័យជលផលតំបន់ឆ្នេរ ធ្វើជំរឿនស្ថិតិទូកនេសាទសមុទ្រ ដែលកំពុងមានសកម្មភាពនេសាទក្នុងដែនសមុទ្រកម្ពុជាជារៀងរាល់ឆ្នាំ ដើម្បីពិនិត្យមើលស្ថានភាពការធ្វើអាជីវកម្មនេសាទសមុទ្រដូចជាការរៀបចំថ្លៃឈ្នួលដែននេសាទសមុទ្រ និង ការចូលរួមដោះស្រាយបាតុភាពសមុទ្រនានា ដែលកើតឡើងជាយថាហេតុ ។

## ២.២ ការគ្រប់គ្រងតាមរយៈសហគមន៍

នៅចុងឆ្នាំ ២០០០ វិស័យជលផល ត្រូវបានកែទម្រង់ដោយរាជរដ្ឋាភិបាលពីការគ្រប់គ្រងដោយឡូតិ៍នេសាទមកការគ្រប់គ្រង ការពារ និង ប្រើប្រាស់ធនធានជលផលដោយសហគមន៍នេសាទក្នុងគោលបំណងធានានិរន្តរភាពធនធានជលផល ។ ផ្ទៃឡូតិ៍នេសាទ ប្រមាណជាងកន្លះលានហិកតាស្មើនឹងជាង៥៦%នៃផ្ទៃឡូតិ៍នេសាទសរុបជិតមួយលានហិកតាទូទាំងប្រទេស ត្រូវបានប្រគល់ជូនសហគមន៍ ភូមិ ឃុំជាអ្នកគ្រប់គ្រងវិញ តាមរយៈការបង្កើតសហគមន៍នេសាទដែលបានចែងក្នុងព្រះរាជក្រឹត្យស្តីពីការបង្កើសហគមន៍នេសាទ និង អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ដែលបានអនុម័តនៅក្នុងខែ មិថុនា ឆ្នាំ ២០០៥ ។ ចាប់តាំងពីឆ្នាំ២០០២ ដល់ បច្ចុប្បន្ន ក្រសួងកសិកម្ម រុក្ខប្រមាញ់ និង នេសាទ បានបង្កើតបានសហគមន៍នេសាទប្រមាណជាង៥០០សហគមន៍ នេសាទហើយ ។ សហគមន៍នេសាទនីមួយៗ ដែលបានបង្កើតឡើងនេះ មានតួនាទី និង ភារកិច្ចចំបង គឺធ្វើការការពារ អភិរក្ស ការគ្រប់គ្រង និង ការប្រើប្រាស់ធនធានជលផលនៅក្នុងសហគមន៍នេសាទរបស់ខ្លួនឱ្យមានចីរភាព ។

## ២.៣ ការបង្កើនផលិតភាព រឺ ផលស្តុកជលផល

ដើម្បីគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព មិនអាចសំរេចបានដោយផ្អែកតែលើការគ្រប់គ្រងការនេសាទតែមួយទេ គឺត្រូវពឹងផ្អែកលើវិធីសាស្ត្រផ្សេងៗទៀតដូចជាការបង្កើនផលិតភាព រឺ ផលស្តុកជលផលតាមរយៈការលែងកូនត្រីពូជក្នុងស្រុកទៅក្នុងបឹង រឺ អាងទឹកធម្មជាតិ និង ការអភិវឌ្ឍន៍វារីវប្បកម្មតាមស្រះ និង បៃ ។

ចាប់តាំងពីឆ្នាំ ២០០៣-២០០៦ រាជរដ្ឋាភិបាល បានប្រារព្ធទិវាមច្ឆជាតិចំនួន៤លើក ដែលបានអញ្ជើញចូលរួមពីសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ ទិវាមច្ឆជាតិ គឺជាទិវាដ៏មានសារៈសំខាន់ ដើម្បីផ្សព្វផ្សាយ និង អប់រំឱ្យប្រជាពលរដ្ឋឱ្យចេះស្រលាញ់ ថែរក្សា និង ការពារមច្ឆជាតិយើងឱ្យមានភាពសំបូរគង់វង្សសំរាប់មនុស្សជំនាន់ក្រោយៗទៀត ។ រហូតមកដល់ពេលបច្ចុប្បន្ន កូនត្រីពូជក្នុងស្រុកប្រមាណជាង១០០លានក្បាល ត្រូវបានលែងចូលទៅក្នុងបឹង រឺ អាងទឹកធម្មជាតិ ។

## ២.៤ ការបង្កើត និង គ្រប់គ្រង តំបន់អភិរក្សជលផល

- បានសហការជាមួយ អង្គការជាតិ និង អន្តរជាតិ និង គណៈកម្មការគ្រប់គ្រងតំបន់ទេសចរផ្សោតទន្លេមេគង្គ ចុះស្រាវជ្រាវអន្លង់ផ្សោតបានចំនួនប្រាំងមួយកន្លែង ដើម្បីធ្វើការអភិរក្សនៅក្នុងខេត្តក្រចេះ និង ស្ទឹងត្រែង ។

- បានដាក់ប៉ុស្តិ៍យាម ចំនួន១៥ប៉ុស្តិ៍ និង បំពាក់សំភារៈមួយចំនួនដូចជា ទូកប្រដេញ និង វិទ្យុទាក់ទងដល់ឆ្មាំទន្លេចំនួន ៦៨នាក់ ដើម្បីធ្វើការការពារ និង អភិរក្សអន្លង់ផ្សោតទាំងប្រាំងមួយអន្លង់នៅក្នុងខេត្តទាំងពីរ ។
- បានបោះបង្គោលក្រាក់ចំនួន ១.៩០០បង្គោល ដាក់គល់ឈើចំនួន ១០០គល់ និង លូស៊ីម៉ង់ចំនួន ៥០០លូទៅក្នុងកន្លែងនេសាទបំរុងទុកចំនួនប្រាំបីកន្លែង ដែលមានផ្ទៃសរុបចំនួន ២៣.៩៤៦ហិកតាក្នុង បឹងទន្លេសាប ។
- បានសហការជាមួយអង្គការអន្តរជាតិ ចុះស្រាវជ្រាវ និង រកឃើញអន្លង់ត្រីសំខាន់ចំនួន ១២៣អន្លង់ នៅជុំវិញបឹងទន្លេសាប និង ចំនួន៩៧អន្លង់នៅខេត្តក្រចេះ និង ស្ទឹងត្រែង ដែលត្រូវបានកំនត់ជាតំបន់អភិរក្សនាអនាគត ។
- បានបោះបង្គោលកញ្ចមនៅក្នុងកន្លែងនេសាទបំរុងទុកទាំងប្រាំងបីក្នុងបឹងទន្លេសាបចំនួន ១៤បង្គោល ដើម្បីកំនត់ព្រំប្រទល់ឱ្យបានច្បាស់លាស់ជៀសវាងកុំឱ្យប្រជាពលរដ្ឋចូលទៅនេសាទ ។
- បានសហការចុះកំណត់ទីតាំងដាក់ប្រអប់សិប្បនិម្មិត និង បង្គោលស៊ីម៉ង់ ចំនួន១.២០០សំរាប់ការពារស្មៅសមុទ្រដែលមានចំនួន២.០០០ហិកតាដើម្បីឱ្យចៀសផុតពីការនេសាទដោយអួនអូសនៅភូមិជ្រោយប្រស់ ឃុំជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង ។
- បានធ្វើការចុះស្រាវជ្រាវ ដើម្បីកំណត់តំបន់អភិរក្សផ្កាថ្ម និង ស្មៅសមុទ្រលើទំហំផ្ទៃក្រឡាចំនួន ២៥.០០០ហិកតានៅក្នុងខេត្តកំពត ។

## ២.៥ ការការពារតំបន់ព្រៃលិចទឹក និង ព្រៃកោងកាង

ព្រៃលិចទឹក និង ព្រៃកោងកាង ជាទីជំរកយ៉ាងស្មុកស្មាញ និង ជាប្រភពផ្តល់ចំនីនិង កន្លែងពងកូនរបស់មច្ឆជាតិ និង វារីសត្វផ្សេងៗទៀត ។ យោងទៅតាមច្បាប់ស្តីពីជលផលរាល់សកម្មភាពទាំងឡាយណាដែលទាក់ទងនឹងការបំផ្លាញព្រៃលិចទឹក និង ព្រៃកោងកាង គឺជាអំពើខុសច្បាប់ ដែលជនល្មើសត្រូវជាប់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំទៅតាមកំរិតទោសដែលជនល្មើសបានប្រព្រឹត្ត ។ ដើម្បីការពារព្រៃលិចទឹក និង ព្រៃកោងកាង រដ្ឋាភិបាល សហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមានសមត្ថកិច្ច សមត្ថកិច្ចជំនាញ ជាពិសេសរដ្ឋអំណាចមូលដ្ឋាន ឃុំ សង្កាត់ ដើម្បីផ្សព្វផ្សាយដល់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង ប្រជាពលរដ្ឋនៅតាមបណ្តាខេត្ត ក្រុងទាំងអស់ឱ្យយល់ដឹងពីសារៈសំខាន់ព្រៃលិចទឹក និង ព្រៃកោងកាង ដើម្បីរិះរកវិធានការទប់ស្កាត់ការកាប់រានព្រៃលិចទឹក និង ពៃកោងកាងពីសំណាក់ប្រជាពលរដ្ឋមូលដ្ឋាន និង អ្នកមានអំណាចមួយចំនួន ។

តាមការស្រាវជ្រាវរបស់គណៈកម្មាធិការទន្លេមេគង្គ អង្គការស្បៀងអាហារកសិកម្ម និង អង្គការGTZ បានបញ្ជាក់ថា រហូតដល់ឆ្នាំ២០០២ ព្រៃលិចទឹក និង ព្រៃកោងកាង ដែលបានដុះតាមវាលទំនាបលិចទឹក មានប្រមាណ ៦៨១.៩០០ហិកតា ដែលក្នុងនោះព្រៃលិចទឹក មានចំនួន ៥៩៦.៤០០ ហិកតា និង ព្រៃកោងកាង មានចំនួន ៨៥.៥០០ ហិកតា ។ ជនល្មើសបានកាប់បំផ្លាញ ដើម្បីធ្វើស្រែប្រាំង និង ដំណាំផ្សេងៗអស់ចំនួន ១០.៩៤៣ ហិកតា ដែលក្នុងនោះព្រៃលិចទឹក មានចំនួន ៩.៦៧២ ហិកតា និង ព្រៃកោងកាងចំនួន ១.២៧១ ហិកតា ។ តាមការស្រាវជ្រាវរបស់រដ្ឋបាលជលផល ក្នុងពេលថ្មីនេះ បានឱ្យដឹងថា មកដល់ពេលនេះ ការកាប់ទន្រ្ទានព្រៃលិចទឹក និង ព្រៃកោងកាង ដើម្បីយកមកធ្វើជាកម្មសិទ្ធនៅក្នុងឡូតិ៍នេសាទ និង កន្លែងនេសាទសហគមន៍ពីសំណាក់ប្រជាពលរដ្ឋ និង អ្នកមានអំណាចមួយចំនួន សរុប ៣៤.៧១២ ហិកតា ដែលក្នុងនោះព្រៃលិចទឹក

ចំនួន ៣៣.៣៤៨ ហិកតា និង ព្រៃកោងកាងចំនួន ១.៣៦៤ ហិកតា ។

ថ្មីៗកន្លងមកនេះរដ្ឋាភិបាល បានសហការជាមួយរដ្ឋបាលជលផល និង អាជ្ញាធរដែនដី បង្កើតជាក្រុមការងារស្រាវជ្រាវ និង គ្រោងដករហូតដី ដែលប្រជាពលរដ្ឋ និង មានអំណាចមួយចំនួន បានរំលោភយកធ្វើជាកម្មសិទ្ធមកទុកជាសម្បត្តិរដ្ឋវិញដោយគិតដល់ពេលបច្ចុប្បន្នមានចំនួន ១៤.១៤៧ ហិកតា ដែលក្នុងនោះខេត្តកណ្តាល មានចំនួន៩.៣២៤ ហិកតា កំពង់ចាមចំនួន ១២៤ហិកតា តាកែវចំនួន ២.០៥៥ហិកតា សៀមរាបចំនួន ៥០០ហិកតា ព្រៃវែងចំនួន ២០ហិកតា ពោធិសាត់ចំនួន ៦០ហិកតា កំពង់ធំចំនួន ២០០ហិកតា កំពង់ឆ្នាំងចំនួន ៦៦១ហិកតា កំពតចំនួន ៤ ហិកតា កោះកុងចំនួន ១៥ហិកតា ក្រុងកែបចំនួន ១៤ ហិកតា និង ក្រុងព្រះសីហនុចំនួន ៩៩០ ហិកតា ។

## ២.៦ ការអភិវឌ្ឍន៍វារីវប្បកម្ម

ចាប់តាំងពីឆ្នាំ២០០២ មកដល់បច្ចុប្បន្ន ការអភិវឌ្ឍន៍វារីវប្បកម្ម មានការចិញ្ចឹមត្រីតាម បែ ស្រះ និង ការចិញ្ចឹមចំរុះជាមួយដំណាំស្រូវ បានការរីកចំរើនគួរឱ្យចាប់អារម្មណ៏ ។ ផលិតផលវារីវប្បកម្មត្រីសាច់បានកើនឡើងពី១៥,០០០តោននៅឆ្នាំ ២០០១ ដល់ ២៦,០០០តោននៅឆ្នាំ ២០០៥ ។ ចំណែកកសិដ្ឋានផលិតកូនត្រីពូជ បានកើនឡើងពី ៦កន្លែង នៅឆ្នាំ២០០១ ដល់ ៦៣កន្លែងនៅឆ្នាំ២០០៥ ហើយ បានផលិតកូនត្រីពូជក្នុងស្រុក និង ក្រៅស្រុក បានចំនួនប្រមាណ១០លានកូនត្រី នៅឆ្នាំ២០០១ ដល់ ២០លានកូនត្រីនៅឆ្នាំ២០០៥ ។ ចំណែកស្រះចិញ្ចឹមត្រី ក៏បានកើនឡើងពី៧០០ស្រះនៅឆ្នាំ ២០០១ ដល់ប្រហែល១២.០០០ស្រះនៅឆ្នាំ២០០៥ និង បែចិញ្ចឹមត្រី បានកើនឡើងពីប្រមាណ ៤០០០បែនៅឆ្នាំ ២០០១ ដល់ ប្រមាណ ៥០០០បែនៅឆ្នាំ២០០៥ ។

## ២.៧ ការងារស្រាវជ្រាវវិទ្យាសាស្ត្រ

វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍នេសាទទឹកសាបត្រូវបានកសាងឡើង នៅឆ្នាំ ២០០៣ ហើយ មានតួនាទីចំបងក្នុងការស្រាវជ្រាវ និង ផ្តល់ព័ត៌មានវិទ្យាសាស្ត្រ ដើម្បីជាប្រយោជន៍ដល់ការធ្វើគោលនយោបាយ យុទ្ធសាស្ត្រ និង ផែនការអភិវឌ្ឍន៍ និង គ្រប់គ្រងវិស័យជលផលប្រកបដោយនិរន្តរភាព ។ ចាប់តាំងពីឆ្នាំ២០០៣ ដល់សព្វថ្ងៃ វិទ្យាស្ថាន បានធ្វើការស្រាវជ្រាវ និង ផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ និង ព័ត៌មានសំខាន់ៗ ដែលទាក់ទងទៅនឹងជីវសាស្ត្ររបស់ត្រី មជ្ឈដ្ឋានរបស់ត្រី ការធ្វើចរាចររបស់ត្រី និង ការពងកូនរបស់ត្រី ទីផ្សារត្រី ឧបករណ៏នេសាទ ការវាយតម្លៃធនធានជលផល និង សេដ្ឋកិច្ចសង្គម និងជីវភាពរស់នៅរបស់ប្រជានេសាទ និង កសិករចិញ្ចឹមត្រី ។ លើសពីនេះទៀត វិទ្យាស្ថាន បានសហការជាមួយបណ្តាអង្គការជាតិ និង អន្តរជាតិមួយចំនួន ដែលបានលែងប្រភេទត្រីដែលកំពុងរងគ្រោះថ្នាក់ រឺ ជិតផុតពូជ ដូចជា ត្រីរាជ ត្រីគល់រាំង ត្រីត្រសក់ ត្រីប្រាធំ ត្រីស្ទក់ ត្រីបបែល អណ្តើក កន្ធាយ ក្រពើ និង ផ្សោត បានចំនួន រាប់ពាន់ក្បាលទៅក្នុងដែនទឹកធម្មជាតិ ក្នុងទិសដៅ ដើម្បីស្រាវជ្រាវអំពីទីជំរក ការធ្វើចរាចរ ការលូតលាស់ និង ពងកូនរបស់ត្រី ព្រមទាំងសំរាប់អភិរក្ស និង ថែរក្សាទុកជាមេពូជសំរាប់កូនចៅជំនាន់ក្រោយ ។

## ៣, វិធានការបន្ត

ដើម្បីសំរេចឱ្យបាននូវ ការពារ អភិរក្ស គ្រប់គ្រង និង ប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព ចាំបាច់ត្រូវអនុវត្តវិធានការមួយចំនួន ដូចតទៅ :

- ពិនិត្យ និង កែលំអឡើងវិញនូវគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ បទដ្ឋានច្បាប់ និង សមត្ថភាពរបស់មន្ត្រីរាជការជលផល តាំងពីថ្នាក់ជាតិ រហូតដល់ មូលដ្ឋាន ឃុំ សង្កាត់ ដើម្បីគាំទ្រ យុទ្ធសាស្ត្រវិមជ្ឈការ និង វិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា ។
- ជំរុញការផ្សព្វផ្សាយ និង អនុវត្តច្បាប់ លិខិតបទដ្ឋានផ្សេងៗ ដើម្បីទប់ស្កាត់ និង បំបាត់ចោលការនេសាទអនាធិបតេយ្យខុសច្បាប់ដូចជា ការកាប់បំផ្លាញព្រៃលិចទឹក ព្រៃកោងកាង និង ការរានទន្ទ្រានកាន់កាប់នាទីដែននេសាទដោយខុសច្បាប់ និង ការនេសាទខុសច្បាប់ ដូចជា ការនេសាទដោយប្រើ ឧបករណ៍ឆក់ ស្បៃមុងរ៉ី ក្រឡាញ៉ឹក ។
- គាំទ្រការបង្កើតតំបន់អភិរក្សនៅក្នុងឡូតិ៍នេសាទ និង កន្លែងនេសាទសហគមន៍ និងពង្រឹងការការពារតំបន់អភិរក្សដូចជា កន្លែងនេសាទបំរុងទុកនៅក្នុងបឹងទន្លេសាប អន្លង់ត្រីនៅជុំវិញបឹងទន្លេសាប អន្លង់ត្រី និង ផ្សោតនៅខេត្តក្រចេះ ស្ទឹងត្រែង និង រតនគិរី និង តំបន់ផ្កាថ្ម និង ស្មៅសមុទ្រនៅតាមតំបន់ឆ្នេរ ។
- លើកកំពស់ និង ធ្វើឱ្យប្រសើរឡើងការគ្រប់គ្រង ធនធានជលផល ដោយសហគមន៍នេសាទនៅទូទាំងប្រទេសតាមរយៈបង្កើត សហគមន៍នេសាទថ្មី និង ពង្រឹងសមត្ថសហគមន៍នេសាទ ដែលមានស្រាប់តាមរយៈ ការកំណត់ព្រំប្រទល់ ការធ្វើផែនការ ការធ្វើលក្ខន្តិកៈ ការកំណត់តំបន់អភិរក្សនៅក្នុងសហគមន៍នេសាទ និង ការធ្វើផែនការគ្រប់គ្រង ដោយមានការចូលរួមយ៉ាងជិតស្និទ្ធបន្ថែមទៀតពីបណ្តា ស្ថាប័នរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន អង្គការជាតិ និង អង្គកាអន្តរជាតិនានា ។
- កសាងសមត្ថភាព និង ផ្ទេរអំណាច រឺ កាទទួលខុសត្រូវដល់សហគមន៍នេសាទ ជាបណ្តើៗ ដើម្បីឱ្យក្លាយខ្លួនទៅជាអ្នកគ្រប់គ្រងធនធានជលផលដ៏សកម្ម និង មានប្រសិទ្ធភាព ។
- លើកកំពស់ការគ្រប់គ្រង និង អភិរក្សជំរកត្រីធម្មជាតិតាមស្រះសហគមន៍ ដើម្បីថែរក្សាត្រីមេពូជសំរាប់ប្រជាជនមូលដ្ឋាននាពេលបច្ចុប្បន្ន និង សំរាប់កូនចៅជំនាន់ក្រោយ ។
- បង្កើនការអភិវឌ្ឍន៍វារីវប្បកម្មជាពិសេសតាមស្រះ និង ការចិញ្ចឹមត្រីក្នុងស្រុកចំរុះជាមួយដំណាំស្រូវទូទាំងប្រទេស ដើម្បីកាត់បន្ថយសម្ពាធលើការសោទត្រីពីធម្មជាតិ ។
- លើកកំពស់ស្មារតី ទិវាមច្ឆជាតិដល់ថ្នាក់មូលដ្ឋាន ឃុំ សង្កាត់ ដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋយើងឱ្យចេះស្រលាញ់ និង ការការពារធនធានជលផលខ្លួន ដើម្បីបង្កើនផលស្តុកត្រីក្នុងដែនទឹកធម្មជាតិ ។
- ធ្វើឱ្យប្រាកដថា មាតា បិតា និង គ្រូបង្រៀន ធ្វើការគូសបញ្ជាក់ និង ប្រាប់ដល់ សិស្ស និង កូនចៅអំពីសារៈសំខាន់ការថែរក្សាព្រៃលិចទឹក ព្រៃកោងកាង និង ផ្លូវទឹកនានា ដើម្បីការពារពូជត្រីក្នុងស្រុកឱ្យស្ថិតនៅគង់វង្សបាន ។
- សិក្សាស្រាវជ្រាវប្រភេទត្រី និង មជ្ឈដ្ឋានរស់នៅរបស់ត្រី និង កំណត់អត្ថប្រយោជន៍សេដ្ឋកិច្ច និង វប្បធម៌ សង្គម

ចេញពីការនេសាទ ដែលជាផ្នែកមួយយ៉ាងសំខាន់នៃការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍នេសាទ ។

- ស្វែងយល់វិធីសាស្ត្រ ដើម្បីពង្រីកតួនាទីរបស់ស្ត្រីនៅក្នុងផលិតកម្មកែច្នៃផលនេសាទ និង ការធ្វើចរាចរផលនេសាទកែច្នៃនៅលើទីផ្សារ ដើម្បីបង្កើនជីវភាពរស់នៅរបស់ស្ត្រី និង គ្រួសាររបស់ពួកគាត់ ។